ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# បូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២១

# និងទិសដៅអនុវត្តបន្ត

រៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# មាតិកា

មាតិកា ..................................................................................................... i
បញ្ជីតារាង ................................................................................................... iii
I.លទ្ធផលការងារ ........................................................................................... 1
កម្មវិធីទី១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ......................................... 1
អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ
និងកិច្ចការគ្រួសារ ........................................................................................ 1
អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា ............................. 4
អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ .................................................. 6
អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ............................................... 6
អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ............................................. 8
កម្មវិធីទី២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាព
ពលកម្មកាយសម្បទាជនពិការ .......................................................................... 8
អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់
មន្ត្រីរាជការស៊ីវិល ........................................................................................ 8
អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់
អតីតយុទ្ធជន និងគ្រួសារ ................................................................................. 9
អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ........... 10
កម្មវិធីទី៣.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ ....................................... 11
អនុកម្មវិធីទី៣.១.ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ ..................................... 11
អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស ........................................................... 11
II-ទិសដៅអនុវត្តបន្ត ......................................................................................... 11
កម្មវិធីទី១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ......................................... 12
អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ ............... 12
និងកិច្ចការគ្រួសារ ........................................................................................ 12

អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា ........ 12

អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ ........ 13

អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ........ 13

អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ........ 14

កម្មវិធីទី២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ ........ 14

អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់ ........ 14

មន្ត្រីរាជការស៊ីវិល ........ 14

អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់ ........ 14

អតីតយុទ្ធជន និងគ្រួសារ ........ 14

អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ........ 14

កម្មវិធីទី៣.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ ........ 15

អនុកម្មវិធីទី៣.១.ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងភាពជាដៃគូ ........ 15

អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស ........ 15

# បញ្ជីតារាង


តារាងទី១ ៖ ជំនួយសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះនិងងាយរងគ្រោះ..........1-2
តារាងទី២ ៖ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំ ទទួលបានប្រាក់ឧបត្ថម្ភកម្មវិធី..........2-
3
តារាងទី៣ ៖ការឧបត្ថម្ភរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជូនមណ្ឌលកុមារកំព្រា.......... 4
តារាងទី៤ ៖ចំនួនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅតាមមជ្ឈមណ្ឌល..........6
តារាងទី៥ ៖ទិន្នន័យធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តរបស់ ប.ជ.ស. ក្នុង ឆមាសទី១ ឆ្នាំ២០២០១..........8
តារាងទី៦ ៖ទិន្នន័យសរុបរបស់សិទ្ធិវន្តដែលធ្វើបច្ចុប្បន្នភាព.......... 8
តារាងទី៧ ៖ទិន្នន័យសិទ្ធិវន្តនៃ ប.ជ.ស. ដែលកំពុងបើករបបតាមប្រព័ន្ធធនាគារក្នុងឆមាសទី១ឆ្នាំ២០២១.....8
តារាងទី៨ ៖កំណត់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារ..........9
តារាងទី៩ ៖លុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព និងទទួលស្គាល់ជាជនពលី និងមរណៈវិញ.....9
តារាងទី១០ ៖លុបឈ្មោះអតីតយុទ្ធជន និងគ្រួសារចេញពីបញ្ជីបើកប្រាក់ប្រចាំឆមាសទី១ ឆ្នាំ២០២១..........9
តារាងទី១១ ៖អតីតយុទ្ធជននិងគ្រួសារ ដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គមក្នុង ឆមាសទី១ឆ្នាំ២០២១...9

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ឆ្នាំ២០២១និងទិសដៅអនុវត្តបន្ត

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១ "ការអភិវឌ្ឍធនធានមនុស្ស"ត្រង់មុំទី៤៖ ការពង្រឹងសមភាពយេនឌ័រ និងកិច្ចគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ បានបង្ហាញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការជួយដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាពិសេស កុមារកំព្រា កុមារងាយរងគ្រោះ ស្ត្រី ជនចាស់ជរា ជនពិការ អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល។

ក្នុងគោលបំណងពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គម រួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ជាពិសេស ជនរងគ្រោះ និងងាយរងគ្រោះ ឱ្យរួចផុតពីហានិភ័យទាំងឡាយ ក្រសួង ស.អ.យ. បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ ផ្តោតលើកម្មវិធីសំខាន់ៗចំនួនបីគឺ១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការនិង ៣.ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ។ អនុកម្មវិធី ១២ រួមមាន ១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ ២.ការអភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា ៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ ៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ៦.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត ៧.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ៨.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ៩.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ១០.ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ ១១.ការអភិវឌ្ឍធនធានមនុស្ស និង១២.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូរាជធានី ខេត្ត។

ជាអាទិ៍ក្នុងឆមាសទី១ឆ្នាំ២០២១នេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអនុវត្តសម្រេចបានលទ្ធផលដូចខាងក្រោម៖

### I.លទ្ធផលការងារ

#### កម្មវិធីទី១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

#### អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ

##### ១.១.១.ការងារសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះនិងងាយរងគ្រោះ

-ក្នុងឆមាសទី១ ឆ្នាំ២០២១នេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការអន្តរាគមក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាជនក្រីក្រ និងងាយរងគ្រោះក្នុងកំឡុងប្រយុទ្ធនឹងជំងឺកូវីដ ១៩ ចំនួន ៦៥២.៤៨៤គ្រួសារ ដែលបានចំណាយទឹកប្រាក់សរុបចំនួន ១.៤០៧.០៦៨.៨០០.០០០៛ ជាលទ្ធផលសរុប គិតចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ រាជរដ្ឋាភិបាលចំណាយថវិកាដ្ឋចំនួន ១,៥២៤,៣៣០,០០៦,០០០៛ (មួយពាន់ ប្រាំរយម្ភៃបួនពាន់ បីរយសាមសិបលាន កៅសិបប្រាំមួយពាន់រៀលគត់)ស្មើនឹង៣៨១.០៨លានដុល្លាអាមេរិកដែលបានគ្របដណ្តប់គ្រួសារប្រមាណចំនួនពីរ ៦៥ម៉ឺន ដល់ ៧០ម៉ឺន ទទួលផលពីការឧបត្ថម្ភសាច់ប្រាក់។

-បានផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាស្បៀងនិងសម្ភារផ្សេងៗដល់ប្រជាជនរងគ្រោះនិងងាយរងគ្រោះចំនួន១៧.០០២គ្រួសារ

តារាងទី១៖ ជំនួយសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះនិងងាយរងគ្រោះ

| ល.រ | រាជធានី/ខេត្ត | ជំនួយសង្គ្រោះ (គ្រួសារ) |
|---|---|---|
| ១ | ក្រសួង ស.អ.យ | ២៥៧ |
| ២ | បន្ទាយមានជ័យ | ៤១១ |
| ៣ | កំពង់ចាម | ៤៩១ |
| ៤ | កំពង់ឆ្នាំង | ៦៣០ |
| ៥ | កំពង់ស្ពឺ | ២ |

| | | |
|---|---|---|
| ៦ | កណ្ដាល | ២៤០ |
| ៧ | ក្រចេះ | ៥៧៨ |
| ៨ | មណ្ឌលគិរី | ៥៤៤ |
| ៩ | រាជធានីភ្នំពេញ | ៤.២៤០ |
| ១០ | ព្រះវិហារ | ១.២៤០ |
| ១១ | ព្រៃវែង | ៨៥៣ |
| ១២ | ពោធិ៍សាត់ | ៦០ |
| ១៣ | រតនគិរី | ៨៨៣ |
| ១៤ | ព្រះសីហនុ | ១៥៥៣ |
| ១៥ | ស្ទឹងត្រែង | ៥១១ |
| ១៦ | ស្វាយរៀង | ៤២៧ |
| ១៧ | តាកែវ | ៣៤០ |
| ១៨ | ឧត្តរមានជ័យ | ១.៣១៨ |
| ១៩ | កែប | ១.០៧០ |
| ២០ | ប៉ៃលិន | ៤០ |
| ២១ | ត្បូងឃ្មុំ | ១១៨ |
| ២២ | អង្គការ The Filed Relief Agency | ១.១៩៦ |
| | | ១៧.០០២ |

### ១.១.២.ការងារជនអនាថា

-បានទទួលជនអនាថា ៩៦៨នាក់ ក្នុងនោះ រាជធានីភ្នំពេញ៩៦៥នាក់បន្ទាយមានជ័យ០១នាក់និងខេត្តរតនគិរី ០២នាក់មកពិគ្រោះយោបល់ អប់រំ និងបញ្ជូនទៅទទួលសេវាបន្តនៅមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញនិងមណ្ឌលរបស់អង្គការដៃគូនិងបានបញ្ជូនត្រឡប់ទៅសហគមន៍វិញ ៣៨០នាក់ ក្នុងនោះ រាជធានីភ្នំពេញ ៣៦៥នាក់ ខេត្តរតនគិរី ០២នាក់ កំពង់ចាម១១នាក់ កំពង់ស្ពឺ ០១នាក់ និងខេត្តកែប ០១នាក់

-មជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅចំនួន៦៦នាក់ និងបានធ្វើសមាហរណកម្មទៅគ្រួសារវិញចំនួន ០២នាក់

-បានចុះត្រួតពិនិត្យតាមដានភាពមិនប្រក្រតីរបស់មន្ត្រីអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារក្រោម ០២ឆ្នាំ នៅខេត្តព្រះសីហនុ

-បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ស្វែងរកធាតុចូលលើសៀវភៅណែនាំស្ដីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំជាមួយមន្ទីរ ស.អ.យ. រាជធានី ខេត្ត ទាំង២៥ តាមប្រព័ន្ធហ្សូមដោយមានអ្នកចូលរួមចំនួន៧៦នាក់។

### ១.១.៣.ការងារគ្រួសារ និងយេនឌ័រ

-គិតត្រឹមថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១ រដ្ឋាភិបាលបានផ្ដល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុ០-២ឆ្នាំ សរុបចំនួន ២១៩.៣៣៣នាក់ ដែលបានចំណាយថវិកាសរុបចំនួន ៥០.៩២៧.៤០០.០០០រៀល។ ដោយឡែក សម្រាប់ឆមាសទី១ ឆ្នាំ២០២១នេះ រាជរដ្ឋាភិបាលបានផ្ដល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុ០-២ឆ្នាំ សរុបចំនួន ៣១.៥០២នាក់ ចំណាយថវិកាអស់ ១៤.១៥៤.០០០.០០០៛

តារាងទី២៖ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំ ទទួលបានប្រាក់ឧបត្ថម្ភកម្មវិធី ឆមាសទី១ ឆ្នាំ២០២១

| ល.រ | រាជធានីខេត្ត | អ្នកទទួលផល (នាក់) | | | ចំនួនស្ត្រី កុមារ និងសម្រាល មកអនុវត្តលក្ខខណ្ឌ | ថវិកា (៛) |
|---|---|---|---|---|---|---|
| | | ស្ត្រី | កុមារ | ចំនួនសម្រាល | ចំនួនលក្ខខណ្ឌ | |
| ១ | បន្ទាយមានជ័យ | ១.២៥០ | ១៤០ | ២១១ | ១២.៧១៩ | ៧៨១.៦០០.០០០ |
| ២ | បាត់ដំបង | ៣.៧៤៧ | ៤៦៤ | ៤៧៨ | ៣៣.៤៨២ | ២០៨.៧១៦.០០០ |
| ៣ | កំពង់ចាម | ១.១៨៨ | ១២២ | ១៩៨ | ១២.០៤៩ | ៧៧៥.៧២០.០០០ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | កំពង់ឆ្នាំង | ៨៣៤ | ៨១ | ១៣៧ | ៧.៦៦៥ | ៤៩២.៣៦០.០០០ |
| ៥ | កំពង់ស្ពឺ | ៤៤០ | ១១១ | ១៧១ | ៥.១៧២ | ៣៤៨.៧២០.០០០ |
| ៦ | កំពង់ធំ | ១.៣៤១ | ១៤៨ | ១៧៦ | ១១.២៣៣ | ៧២២.១៦០.០០០ |
| ៧ | កំពត | ៩២៥ | ៧០ | ១៣៤ | ៧.៩៤០ | ៥១៦.៨៤០.០០០ |
| ៨ | កណ្តាល | ៨៧៥ | ១៤៨ | ២៣៥ | ១០.៧៩២ | ៦៩៣.៨៤០.០០០ |
| ៩ | កោះកុង | ២៨៤ | ៣៦ | ៣៧ | ២.០៨២ | ១៥០.៣៦០.០០០ |
| ១០ | ក្រចេះ | ១.២៦៦ | ២០៩ | ៣១១ | ១១.២៤០ | ៧៤៧.៦០០.០០០ |
| ១១ | មណ្ឌលគិរី | ២០៩ | ៣៣ | ៥២ | ១.៩៧១ | ១៣០.១២០.០០០ |
| ១២ | ភ្នំពេញ | ៦៧០ | ២២៦ | ៤៦៨ | ៨.០០៥ | ៧៤៣.២៤០.០០០ |
| ១៣ | ព្រះវិហារ | ៧៧៦ | ១០១ | ១៤៨ | ៧.៣០២ | ៤៦៩.២៤០.០០០ |
| ១៤ | ព្រៃវែង | ១.២៤១ | ១៧០ | ៣១៣ | ១៣.៣៣៦ | ៨៤៥.៤៤០.០០០ |
| ១៥ | ពោធិ៍សាត់ | ៨៦៥ | ១១៨ | ១២៩ | ៨.៥២០ | ៥៣៦.១៦០.០០០ |
| ១៦ | រតនគិរី | ៥២៥ | ៥២ | ៨៤ | ៤.១៤០ | ២៩០.២៨០.០០០ |
| ១៧ | សៀមរាប | ១.៩៣៩ | ២៤៧ | ១៥០ | ១៤.៣២០ | ៨៦៤.០០០.០០០ |
| ១៨ | ព្រះសីហនុ | ២៣៧ | ៣៧ | ១.៩២២ | ២.៥០៩ | ៥៣៧.០០០.០០០ |
| ១៩ | ស្ទឹងត្រែង | ៤៣០ | ៤៧ | ៨២ | ៣.៣០៧ | ២២៥.៦៨០.០០០ |
| ២០ | ស្វាយរៀង | ៤២៤ | ៥៥ | ១១១ | ៤.៦៣៤ | ២៩៥.៨៤០.០០០ |
| ២១ | តាកែវ | ៩៣៣ | ១២៩ | ១៧៨ | ១០.២២៩ | ៦៥០.៧៦០.០០០ |
| ២២ | ឧត្តរមានជ័យ | ៥៦៤ | ៦៣ | ៨២ | ៥.៦១២ | ៣៣៥.២៤០.០០០ |
| ២៣ | កែប | ៤៩ | ៦ | ៤ | ៤៦៩ | ២៩.៦០០.០០០ |
| ២៤ | ប៉ៃលិន | ២២៨ | ២២ | ៦៥ | ២.៥៩៩ | ១៦៤.៥៦០.០០០ |
| ២៥ | ត្បូងឃ្មុំ | ១.២០៩ | ១៣៩ | ២០៣ | ១២.៦២៥ | ៧៦០.៤៨០.០០០ |
| សរុប | | ២២.៤៤៩ | ២.៩៧៤ | ៦.០៧៩ | ២១៣.៩៥២ | ១៤.១៥៤.០០០.០០០ |

### ១.១.៤.ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងការធ្វើសមាហរណកម្មជនរងគ្រោះ

-បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទដែលត្រូវបានធ្វើមាតុភូមិវត្តន៍ និងទទួលពីប្រទេសនានាសរុបចំនួន ១៨៤នាក់ ស្រី១៦៤នាក់ មកពីប្រទេសចិន ១៣៧នាក់ វៀតណាម១៤នាក់ ឥណ្ឌូនេស៊ី ០២នាក់ ម៉ាឡេស៊ី ១៤នាក់ ថៃ ១៤ និងសិង្ហបុរី ០៣នាក់ និងបានធ្វើសមាហរណកម្មត្រឡប់ទៅសហគមន៍វិញចំនួន ១៨នាក់

-បានទទួលជនរងគ្រោះដែលនិរទេសពីប្រទេសថៃ៣៦.៥៩៣នាក់ ស្រី ១៦.៣៥៤នាក់ និងបានធ្វើការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ និងបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ

-បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សសរុបចំនួន ៥៧នាក់ ស្រី ៥៣នាក់ និងបានបញ្ជូនទៅស្តារនីតិសម្បទានៅមជ្ឈមណ្ឌលរបស់អង្គការដៃគូ និងបានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សត្រឡប់ទៅសហគមន៍វិញចំនួន ៥២នាក់។

-បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទដែលបានទទួលពីនគរបាលមានសមត្ថកិច្ចក្នុងស្រុកសរុបចំនួន០៣នាក់ ជាជនជាតិវៀតណាម

-បានបិទករណីសរុបចំនួន ០២នាក់(ស្ត្រី) ជាករណីរំលោភបំពានផ្លូវភេទ

-បានចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលមានកិច្ចព្រមព្រៀងជាមួយក្រសួងស.អ.យ. ចំនួន១៧អង្គការមណ្ឌល និងមណ្ឌលសំចតបោយប៉ែតដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប បន្ទាយមានជ័យនិងខេត្តបាត់ដំបង។

**អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា**

**១.២.១.ការងារមជ្ឈមណ្ឌលកុមារកំព្រានិងការថែទាំកុមារ**

-នៅឆ្នាំ២០១៩ ក្រសួងបានធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងចំនួន ២៣២កន្លែង កុមារសរុបចំនួន ៦.៧៧៨នាក់ កុមារី ៣.៣១៧នាក់ និងយុវជនវ័យក្មេងអាយុ ១៨ឡើង១.៧៩២នាក់ ស្រី ៩២៩នាក់ (មណ្ឌលរដ្ឋចំនួន២១មណ្ឌល មានកុមារ៧៨៩នាក់ កុមារី ៣២៤នាក់ និងយុវជនវ័យក្មេងអាយុ១៨ឡើង ៣៦០នាក់ ស្រី១៨៤នាក់) មណ្ឌលអង្គការ២១១មណ្ឌល មានកុមារ៥.៩៨៩នាក់ កុមារី២.៩៨៩នាក់ និងយុវជនវ័យក្មេងអាយុ១៨ឡើង១.៤៣២នាក់ ស្រី ៧៤៥នាក់។ ការថែទាំតាមបែបសហគមន៍មានចំនួន ១២៨កន្លែង កុមារសរុបចំនួន២.៨០០នាក់ កុមារី១.២៩៤នាក់ និងយុវជនវ័យក្មេងអាយុ១៨ឡើង ៧៧៥នាក់ ស្រី៣១២នាក់។មណ្ឌលកុមារកំព្រាមួយចំនួនទទួលការឧបត្ថម្ភបន្ថែមពី**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក្នុងនោះៈ

តារាងទី៣ៈ ការឧបត្ថម្ភរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជូនមណ្ឌលកុមារកំព្រា

| **ល.រ** | **ឈ្មោះមណ្ឌល/អង្គការ** | **ការឧបត្ថម្ភ** | | |
|---|---|---|---|---|
| | | **អង្ករ** | **ថវិកា** | **សម្ភារ** |
| ១ | បុរីទារក និងកុមារជាតិ | | ១០លានរៀល/ឆ្នាំ | គ្រឿងបរិភោគ/ឆ្នាំ |
| ២ | មណ្ឌលសាលាគថ្លង់ភ្នំពេញថ្មី | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៣ | មណ្ឌលសាលាគថ្លង់ច្បារអំពៅ | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៤ | មណ្ឌលកុមារកំព្រាភ្នំពេញថ្មី | ៥០០គីឡូក្រាម/ខែ | ១លានរៀល/ខែ | |
| ៥ | មជ្ឈមណ្ឌលកូលាបទី៤ | | ៣លានរៀល/ខែ | |
| ៦ | មណ្ឌលផ្កាម្លិះ | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៧ | សមាគមជនគ្មានទីពឹង | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៨ | បុរីកុមារមិត្តភាពកម្ពុជាបារាំងហុងគ្រី | | ១.៩លានរៀល/ខែ | |

**១.២.២.ការងារថែទាំជំនួសចំពោះកុមារ និងអភិការកិច្ច**

-បានចុះពិនិត្យ និងវាយតម្លៃទទួលស្គាល់មណ្ឌលថែទាំកុមាររបស់អង្គការ ដូចជា មណ្ឌលកុមារកំព្រាដើរឹឧខេត្តឧត្តរមានជ័យ មណ្ឌលកុមារអភិវឌ្ឍន៍ថ្មីខេត្តកំពង់ឆ្នាំង មណ្ឌលកុមារកំព្រាដែលម៉ុនកម្ពុជាខេត្តបន្ទាយមានជ័យ មណ្ឌលស្នាក់នៅបណ្តោះអាសន្នខេត្តព្រះសីហនុ សហគមន៍អូរព៍ន្ធខេត្តតាកែវ និងមណ្ឌលកុមារសន្តិភាពខេត្តបាត់ដំបង

-បានចេញប្រកាស ស្តីពីនីតិវិធីការអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌

-បានផ្តល់បច្ចេកទេស ស្តីពីការធ្វើអធិការកិច្ចកន្លែងថែទាំកុមារដល់មន្ត្រីបង្គោលខេត្តចំនួន ១០ រួមមាន ខេត្តព្រះវិហារ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ក្រចេះ ប៉ៃលិន ព្រៃវែង ស្វាយរៀង កំពង់ចាម និងខេត្តកំពង់ស្ពឺ

-បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងករណីតាមប្រព័ន្ធបច្ចេកវិទ្យា (Primeroជាកម្មវិធីសម្រាប់គ្រប់គ្រងករណីរបស់កុមារដែលបានចូលរស់នៅក្នុងមណ្ឌលថែទាំកុមារដោយអាចប្រើប្រាស់បាននៅលើទូរស័ព្ទដៃ កុំព្យូទ័រ ឬថេបប្លេត) ដល់មន្ត្រីបង្គោល បុគ្គលិកសង្គមកិច្ច មន្ត្រីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក នៃខេត្តបន្ទាយមានជ័យ ដែលមានអ្នកចូលរួមចំនួន១៥នាក់

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនការប្រតិបត្តិការថ្នាក់ខេត្ត ស្តីពីកិច្ចការពារកុមារនៅខេត្តព្រៃវែង ក្រចេះ និងខេត្តបន្ទាយមានជ័យ

-បុរីទារក និងកុមារជាតិ មានកុមារស្នាក់នៅសរុបចំនួន ១៤៧នាក់ ស្រី ៦៩នាក់ ក្នុងនោះ កុមារពិការ ១២៦នាក់ កុមារផ្ទុកមេរោគអេដស៍ ១២នាក់ និងកុមារធម្មតា ០៩នាក់។

-បានរៀបចំចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងក្រសួង ស.អ.យ.ជាមួយអង្គការស៊ីការស្វាអង្គការWorld vision អង្គការពីគ្រួសារមួយទៅគ្រួសារមួយ និងអង្គការពន្លឺអនាគត

-បានរៀបចំ និងបោះពុម្ពសៀវភៅមេរៀន ស្តីពីយុទ្ធសាស្ត្រទាំងប្រាំពីរ (INSPIRES គឺជាយុទ្ធសាស្ត្រសកល ដែលបានប្រើប្រាស់សម្រាប់បញ្ចប់អំពើហិង្សាលើកុមារ) ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ចំនួន ៥៥០ក្បាល សម្រាប់ចែកជូនមន្ត្រី

ដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាល ព្រមទាំងបានបណ្តុះបណ្តាលចំនួន ២វគ្គតាមប្រព័ន្ធអនឡាញ គឺនៅខេត្តបាត់ដំបង និងខេត្តសៀមរាបដែលមានអ្នកចូលរួមចំនួន ១៦០នាក់

-បានរៀបចំផែនការផ្សព្វផ្សាយ "យុទ្ធនាការគ្រួសាររឹងមាំ" ដើម្បីលើកកម្ពស់ការយល់ដឹងដើម្បីលុបបំបាត់អំពើហិង្សាលើកុមារក្នុងរាជធានី ខេត្តគោលដៅទាំង ០៦ នៅក្រសួងស.អ.យ.

-បានផ្សព្វផ្សាយយុទ្ធនាការ "គ្រួសាររឹងមាំ" ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់សរុបចំនួន ៤៥អត្ថបទ ផ្សព្វផ្សាយចំនួន ៨៨ដង នៅលើបណ្តាញសង្គម facebookដែលមានអ្នកចូលមើលចំនួន ៣.៨៧៧.០២៣នាក់ មានអ្នចូលរួម៣០៧.៣៦២នាក់ មានអ្នកស៊ែបន្តចំនួន ២.៤៥២នាក់ និងអ្នកតាមដានបណ្តាញសង្គមថ្មីចំនួន១៦.៦៤២នាក់

-បានចាក់ផ្សាយវីដេអូរអប់រំដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ នៅប៉ុស្តិ៍ CTN និងMyTV

-បានរៀបចំសិក្ខាសាលាស្តីពីការចុះស្រង់ទិន្នន័យ និងការប៉ាន់ប្រមាណកុមារដែលត្រូវធ្វើផែនការអចិន្ត្រៃយ៍ តាមរយៈប្រព័ន្ធ Zoom ជាមួយមន្ទីរ ស.អ.យ. រាជធានីភ្នំពេញ

-បុរីទារក និងកុមារជាតិ មានកុមារស្នាក់នៅសរុបចំនួន ១៤៧នាក់ ស្រី ៦៩នាក់ ក្នុងនោះ កុមារពិការ ១២៦នាក់ កុមារផ្ទុកមេរោគអេដស៍ ១២នាក់ និងកុមារធម្មតា ០៩នាក់។

### ១.២.៣.ការងារសុំកូនអន្តរប្រទេស

-បានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យនូវសំណុំឯកសារចាស់ៗនៃការសុំកូនអន្តរប្រទេសចំនួន ១៥០ករណី

-បានទទួលរបាយការណ៍ស្តីពីការវិវឌ្ឍរបស់កូនសុំ ១៥៧ករណី មកពីប្រទេសអ៊ីតាលីចំនួន ១៤៧ករណី អូទ្រីស ០៨ករណី និងម៉ាល់តា ០២ករណី។ តាមការវាយតម្លៃ ស្ថានភាពកូនមានលក្ខណៈល្អប្រសើរទាំងផ្នែក សុខភាព ការរស់នៅ និងសិក្សារៀនសូត្រ។

### ១.២.៤.ការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក)

-បានរៀបចំសិក្ខាសាលាស្តីពីការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ នៅខេត្តសៀមរាប រតនគិរី និងខេត្តស្ទឹងត្រែង ក្នុងគោលបំណងជំរុញការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ការកំណត់រកដំណោះស្រាយជាយុទ្ធសាស្ត្រ និងឱកាសនៃកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធដែលមានសមាសភាពអ្នកចូលរួមសរុបចំនួន ៤០៧នាក់ ស្រីចំនួន ២៥០នាក់

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារ និងយុវជនលើសេចក្តីព្រាងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធការពារកុមារឆ្នាំ២០១៩-២០២៩ ដែលមានអ្នកចូលរួមចំនួន៨៨នាក់ ស្រី៤៩នាក់

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើសេចក្តីព្រាងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ដែលមានអ្នកចូលរួមសរុប៥៣នាក់និង ស្រី១៦នាក់

-បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសគណៈកម្មការការពារកុមារថ្នាក់ជាតិដើម្បីស្នើសុំធាតុចូលបន្ថែម និងសុំការឯកភាពលើសេចក្តីព្រាងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ ២០១៩-២០២៩ នៅខេត្តព្រះវិហារ ដែលមានអ្នកចូលរួមចំនួន ៣៧នាក់ និងស្រី ៧នាក់

-បានសម្របសម្រួលរៀបចំកិច្ចពិភាក្សាតុមូល និងកិច្ចពិភាក្សាតាមវិទ្យុ នៅស្ថានីយ៍វិទ្យុ និងទូរទស្សន៍បាយ័ន្ត ក្រោមប្រធានបទ "១.ការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារនិង២.ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីធឺណែត"

-បានរៀបចំកិច្ចប្រជុំត្រៀមសម្រាប់គណៈប្រតិភូអន្តរក្រសួងចូលរួមកិច្ចប្រជុំលើកទី៨៧ ដើម្បីការពាររបាយការណ៍ជាតិលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ

-សម្របសម្រួលរៀបចំក្រុមការងារបច្ចេកទេសអន្តរក្រសួង មានក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌ ជាសេនាធិការផ្ទាល់លើសេចក្តីថ្លែងការណ៍រួម ស្តីពីការប្តេជ្ញាចិត្តទប់ស្កាត់ការដកហូតទប់ស្កាត់សិទ្ធិសេរីភាពរបស់កុមារនៅកម្ពុជា

-បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុស្ត្រី ១០២.៥ ក្រោមប្រធានបទ "អំពើហិង្សាលើស្ត្រី និងកុមារ"

-បានចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីកិច្ចសន្ទនា ស្តីពីប្រភេទ និងទម្រង់នៃអំពើហិង្សា និងការរំលោភបំពានតាមប្រព័ន្ធអនឡាញមកលើកុមារ ជាពិសេសក្មេងស្រី។

**១.២.៥.ការងារយុវនីតិសម្បទា**

**១.២.៥.១.ការអប់រំទប់ស្កាត់កុមារ យុវជនប្រព្រឹត្តបទល្មើសនិងសេពគ្រឿងញៀន**

-បានធ្វើបច្ចុប្បន្នភាពអនីតិជនទំនាស់នឹងច្បាប់នៅតាមពន្ធនាគារ និងមណ្ឌលអប់រំកែប្រែតាមរាជធានី ខេត្ត មានអនីតិជនសរុបចំនួន ១.២៨៣នាក់ ស្រី ៥៣នាក់

-បានសហការជាមួយអង្គការសម្ព័ន្ធមេត្រីភាពពន្ធនាគារ ផ្តល់សេវាគាំទ្រផ្នែកសម្ភារសិក្សា សុខភាព និងសុវត្ថិភាពដល់កូនជនជាប់ឃុំសរុប ៩០២នាក់ ស្រី ៤២៧នាក់។

**១.២.៥.២.ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន**

-បានកែសម្រួលសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី បែបបទ និងនីតិវិធីការផ្ទេរ ប្រគល់ទទួលការគ្រប់គ្រង បញ្ជីឈ្មោះ និងនីតិវិធីដោយឡែកការរៀបចំ ចំណាត់ថ្នាក់សន្តិសុខទណ្ឌិត និងអនីតិជនជាប់ឃុំនៅក្នុងមណ្ឌលយុវនីតិសម្បទា

-បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ទម្រង់របាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ចំនួន ២វគ្គ នៅខេត្តបាត់ដំបង និងខេត្តកំពត

-ភ្នាក់ងារសង្គមកិច្ចខេត្តកំពង់ចាមបានចុះតាមដាម និងសួរសុខទុក្ខអនីតិជនចំនួន៤នាក់ដែលទទួលជីការបង្វែរឱ្យទៅរស់នៅសហគមន៍ស្រុកកំពង់សៀម និងក្រុងកំពង់ចាម

-បានរៀបចំសេចក្តីប្រកាសអន្តរក្រសួង រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មហាផ្ទៃ និងក្រសួងយុត្តិធម៌ ស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរ ប្រគល់ ទទួលគ្រប់គ្រង និងស្តារនីតិសម្បទាអនីតិជនទំនាស់និងច្បាប់

-បានចេញប្រកាសបញ្ចូលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ៧.៥៦៥នាក់ ស្រី ៣៣១នាក់ និងចេញប្រកាសបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ៧.៥៥១នាក់ ស្រី ៣០០នាក់ ដូចនេះ នៅសល់ជាក់ស្តែងចំនួន ៣.៩៧១នាក់ ស្រី ១៨១នាក់

តារាងទី៤ ៖ ចំនួនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅតាមមជ្ឈមណ្ឌល

| ល.រ | មជ្ឈមណ្ឌល | សល់ក្នុងឆ្នាំ២០២០ | | បញ្ចូលក្នុង ឆមាសទី១ ឆ្នាំ២០២១ | | សមាហរណកម្មក្នុងឆមាសទី១ ឆ្នាំ ២០២១ | | សល់ជាក់ស្តែងក្នុងឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរាជធានីភ្នំពេញ | ២៨៨ | ១០ | ៣៥២ | ០៤ | ៥៣៦ | ១២ | ១០៤ | ០២ |
| ២ | មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀនខេត្តព្រះសីហនុ | ១០៣ | ០០ | ៣៦ | ០០ | ១២០ | ០០ | ១៩ | ០០ |
| ៣ | ជីវិតថ្មីភ្នំបាក់ខេត្តបន្ទាយមានជ័យ | ៦៧៦ | ៣៨ | ៦៥១ | ៣៤ | ៦០០ | ៣៧ | ៧២៧ | ៣៥ |
| ៤ | ឱកាសខ្ញុំរាជធានីភ្នំពេញ | ២.១៩៨ | ១០៣ | ២.២៧៩ | ១២៥ | ២.៧២១ | ១២១ | ១.៧៥៦ | ១០៧ |
| ៥ | ពិភពនៃក្តីសង្ឃឹមខេត្តបាត់ដំបង | ៣០៥ | ០០ | ២៤៨ | ០០ | ៣៨៨ | ០០ | ២៦៤ | ០០ |
| ៦ | កងរាជអាវុធហត្ថខេត្តបាត់ដំបង | ៨១ | ០០ | ១៦ | ០០ | ១៩ | ០០ | ៧៨ | ០០ |
| ៧ | បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| ៨ | ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនខេត្តសៀមរាប | ៤០០ | ១០ | ៦៨៩ | ០០ | ៦៨៣ | ១០ | ៤០ | ០០ |
| ៩ | បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះសីហនុ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| | សរុប | ៤.០៥១ | ១៦១ | ៤.២៧១ | ១៦៣ | ៥.០៦៧ | ១៨០ | ២.៩៨៨ | ១៤៤ |

**អនុកម្មវិធីទី១.៣.ការលើកកម្ពស់សុខុមាលភាពជនពិការ**

-បានរៀបចំពិធីចែកអំណោយដ៏ថ្លៃថ្លារបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ចែកជូនដល់សមាគមគ្រូស្ត្រីជនពិការ និងបងប្អូនជនពិការរស់នៅក្នុងអង្គការ PPCIL

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើការវិសោធនកម្មច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធជនពិការជាមួយអង្គការតំណាងជនពិការ និងសង្គមស៊ីវិល នៅសណ្ឋាគារសាន់វេ និងសណ្ឋាគារភ្នំពេញ

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាពសម្រាប់រាជធានី ខេត្តទាំង ២៥ ដែលមានអ្នកចូលរួមសរុបចំនួន ៤៦នាក់ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី

-បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការផ្សព្វផ្សាយបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ និងកម្រងឯកសារបណ្តុះបណ្តាល នៅសណ្ឋាគារ សាន់វេ

-បានសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពលើការធ្វើបរិយាបន្នពិការភាព នៃគម្រោង ពង្រឹងសមត្ថភាព និងការអប់រំសម្រាប់ជនពិការ ដល់មន្ត្រីពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅភោជនីយដ្ឋាន ទន្លេបាសាក់២

-បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការជាមួយសមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ និងតំណាងក្រសួងពាក់ព័ន្ធ ចំនួន៣លើក នៅសណ្ឋាគារ ភ្នំពេញ

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល សម្រាប់ជនពិការ ជូនសមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការនៅខេត្តសៀមរាប

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការកសាងផែនការសកម្មភាពស្តារឡើងវិញក្រោយវិបត្តិជំងឺកូវីដ១៩ សម្រាប់ជនពិការនៅសណ្ឋាគារភ្នំពេញ

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកម្ពស់ការអនុវត្តផែនការស្តារឡើងវិញក្រោយជំងឺកូវីដ១៩ សម្រាប់ជនពិការ និងឧបករណ៍ស្វែងរកការគាំទ្រនៅសណ្ឋារគារភ្នំពេញ

-បានរៀបចំកិច្ចប្រជុំពិនិត្យលើផែនការស្តារឡើងវិញរយៈពេល៣ឆ្នាំចំពោះជនពិការក្នុងកំឡុងពេលរងផលប៉ះពាល់ដោយជំងឺកូវីដ ១៩ នៅសណ្ឋាគារ ប៉ាប៉ាឌីសៀមរាប

-បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពី ការធ្វើបរិយាបន្ននៅក្នុងដំណើរការរៀបចំ និងការកសាងកម្មវិធីវិនិយោគឃុំសង្កាត់ នៅសណ្ឋាគារ ភ្នំពេញ

-បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ស្តីពីការកំណត់អត្តសញ្ញាណកម្មពិការភាព តាមបែបគំរូសង្គម និងសិទ្ធជាមូលដ្ឋានសម្រាប់ថ្នាក់ខេត្តចំនួន ៧វគ្គ គឺមានរាជធានីភ្នំពេញ ខេត្តតាកែវ កំពង់ស្ពឺ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កំពង់ឆ្នាំង កែប កំពត កោះកុង កណ្តាល ព្រះសីហនុ ព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី ដែលមានអ្នកចូលរួមសរុប ៣៨៧នាក់

-បានចេញលិខិតបញ្ជាក់ពិការភាពជូនជនពិការចំនួន ០៤នាក់ ដើម្បីយកទៅប្រើប្រាស់ផ្សេងៗ

-បានផលិតសៀវភៅមគ្គុទេសក៍គតិយុត្តស្តីពីកាតព្វកិច្ចរបស់និយោជក ក្នុងការជ្រើសរើស និយោជិតពិការចូលបម្រើការងារ ចំនួន១០.០០០ក្បាល ដើម្បីចែកជូនដល់ ក្រុមហ៊ុន រោងចក្រ សហគ្រាស ទូទាំងប្រទេស

-បានផលិតវីដេអូចំនួន ៥ស្ពត ណែនាំសម្រាប់មន្ត្រីដែលត្រូវអនុវត្តកំណត់អត្តសញ្ញាណកម្មពិការភាពតាមឃុំ សង្កាត់

-មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ (JCIA)បានបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការក្នុងវគ្គទី២២ ឆ្នាំ២០២១ សរុបចំនួន ៣៥នាក់ ស្រី ០៦នាក់ ក្នុងនោះ ផ្នែកកាត់ដេរសំលៀកបំពាក់ អ៊ុតសក់ និងសំអាងកាយ ០៧នាក់ ផ្នែកជួសជុលវិទ្យុទូរទស្សន៍និងបរិក្ខាអគ្គិសនី ១៣នាក់ និងផ្នែកជួសជុល ម៉ូតូ ម៉ាស៊ីនតូចធំ ១៥នាក់

-បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការសម្របសម្រួលវគ្គពិការភាពបរិយាបន្ន

-បានពិនិត្យ កែសម្រួលរបាយការណ៍ ស្តីពីការអនុវត្តស្តីពីសិទ្ធិជនពិការ

-បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យគម្រោងសាងសង់ជម្រាលសាកល្បងនៅតាមខេត្តគោលដៅ

-បានពិនិត្យ និងឆ្លើយតបទៅលើសំណើសុំផ្តល់ធាតុចូលរបស់អង្គការដៃគូពាក់ព័ន្ធ លើសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចគាំពារជនមានពិការភាព

-បានរៀបចំឯកសារទស្សនទានក្នុងការស្រង់ទិន្នន័យហ័សរបស់ជនពិការដើម្បីទទួលបានការចាក់វ៉ាក់សាំងកូវីដ ១៩

-បានចេញប្រកាសទទួលស្គាល់ជនពិការក្រីក្រដើម្បីទទួលបានរបបគោលនយោបាយជនពិការក្រីក្រនៅតាមសហគមន៍ ចំនួន ៦២៤នាក់ នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

-បានបោះពុម្ពកាតចំនួន ១២.០០០០ សម្រាប់ផ្តល់ជូនជនពិការដែលបានស្នើប័ណ្ណសម្គាល់ជនមានពិការភាព

-បានចេញប្រកាសលុបឈ្មោះជនពិការដែលទទួលបានរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ដែលបានទទួលមរណភាព ក្នុងខេត្តកំពត បាត់ដំបង កណ្តាល និងខេត្តព្រៃវែងចំនួន ៣១៩នាក់។

**អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

-បានប្រមូលធាតុចូលពីក្រសួង ស្ថាប័ន ដើម្បីរៀបចំផែនការសកម្មភាព២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០

-ពិនិត្យ និងកែសម្រួលអនុក្រឹត្យ លេខ១៥៨អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សវ័យចាស់

-បានសហការជាមួយអង្គការ UNDP រៀបចំឯកសារទស្សនទានក្នុងការរៀបចំផែនការសកម្មភាពឆ្នាំ២០២១-២០២៥ នៃការអនុវត្តគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ និងបានប្រមូលធាតុចូលពីក្រសួង ស្ថាប័ន ដើម្បីរៀបចំផែនការសកម្មភាព២០២១-២០២៥នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។

**អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន**

-គិតមកដល់បច្ចុប្បន្ន សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាសរុបចំនួន ៧៩.១៩៥នាក់

-បានទទួលសំណុំបែបបទស្នើសុំប្រាក់បេឡាមរណសង្គ្រោះពី ស.អ.ក. រាជធានី ខេត្តចំនួន ៩៧៨សព។ គិតពីឆ្នាំ ២០០៨ មកដល់ត្រឹមថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ គណៈអចិន្ត្រៃយ៍ ស.អ.ក. បានទទួលសំណុំបែបបទស្នើសុំប្រាក់ ប.ម.ស. សរុបចំនួន ១៧.២២៦សព និងបានចេញសេចក្តីសម្រេចស្តីពីការប្រគល់ថវិកា ប.ម.ស. ជូនសមាជិក ស.អ.ក ទាំងស្រុង។

***កម្មវិធីទី២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ***

**អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**

-បានរៀបចំបែបបទទទួលស្គាល់មន្ត្រីរាជការឱ្យចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គម ចំនួន ៦៨៤នាក់ និងអ្នកនៅក្នុងបន្ទុក ៥២០នាក់ ព្រមទាំងផ្ទេរការគ្រប់គ្រងទៅតាមរាជធានី ខេត្ត

-បានចេញប្រកាសលុបសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈសរុបចំនួន ១.១១៥នាក់ និងបន្តឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកចំនួន ៧២៦នាក់

-កែសម្រួលកាំប្រាក់សោធនជូននិវត្តជន ៩០នាក់

-បានលុបអ្នកនៅក្នុងបន្ទុក ១.១១៩នាក់

-បានបើកប្រាក់នៅសល់ក្នុងគណនីជូនគ្រួសារសព និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ ២៧៧នាក់

-បានបើកប្រាក់របបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន និងគ្រួសារសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ៧៤៦នាក់

-បានបើកប្រាក់របបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកសពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបន្ទុករបស់សពមន្ត្រីរាជការស៊ីវិលចំនួន ១១.២៦៧នាក់

-បានផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជំងឺស្នើសុំផ្ទេរសិទ្ធិចំនួន ៤២នាក់

<u>តារាងទី៥៖ ទិន្នន័យធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តរបស់ ប.ជ.ស. ក្នុងឆមាសទី១ ឆ្នាំ២០២១</u>

| ល.រ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | | | | |
|---|---|---|---|---|---|---|---|
| | | | ប្រពន្ធ | កូន | ប្រពន្ធសព | កូនសព | កូនសពមន្ត្រីរាជការស៊ីវិល |
| ១ | និវត្តជន | ៦៤៤ | ២០៧ | ៨៦ | ០៤ | ១៤ | ០ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ០ | ០ | ០ | | ០ | |
| ៣ | អ្នកនៅក្នុងបន្ទុក | ៣១១ | ២០៧ | ៨៦ | ០៤ | ១៤ | ០ |
| សរុបរួម | | ៩៥៥ | | | | | |

(ប្រភព ប.ជ.ស.)

<u>តារាងទី៦៖ ទិន្នន័យសរុបរបស់សិទ្ធិវន្តដែលធ្វើបច្ចុប្បន្នភាពគិតត្រឹមឆមាសទី១ ឆ្នាំ២០២១</u>

| ល.រ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | | | | |
|---|---|---|---|---|---|---|---|
| | | | ប្រពន្ធ | កូន | ប្រពន្ធសព | កូនសព | កូនសពមន្ត្រីរាជការស៊ីវិល |
| ១ | និវត្តជន | ៥៦.៤៥៦ | ៣០.៨៤២ | ៣.៣៥០ | ៨.២៩១ | ២៧៣ | ១២៨ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ១.៨៩០ | ៨១៤ | ០២ | ៩៤៣ | ៦ | |
| ៣ | អ្នកនៅក្នុងបន្ទុក | ៤៤.៦៤៩ | ៣១.៦៥៦ | ៣.៣៥២ | ៩.២៣៤ | ២៧៩ | ១២៨ |
| សរុបរួម | | ១០២.៩៩៥ | | | | | |

(ប្រភព ប.ជ.ស.)

<u>តារាងទី៧៖ ទិន្នន័យសិទ្ធិវន្តនៃ ប.ជ.ស. ដែលកំពុងបើករបបតាមប្រព័ន្ធធនាគារគិតត្រឹមខែមិថុនាឆ្នាំ២០២១</u>

| ល.រ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | |
|---|---|---|---|---|
| | | | ប្រពន្ធ | កូន |
| ១ | និវត្តជន | ៥៤.៩៤៩ | ២៩.៨២៩ | ៤.០០០ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ១៧៥២ | ៧៤៤ | ០៤ |
| ៣ | អ្នកនៅក្នុងបន្ទុក | ៣៤.៥៧៧ | ៣០.៥៧៣ | ៤.០០៤ |

| | | |
|---|---|---|
| សរុបរួម | ៩១.២៧៨ | (ប្រភព ប.ជ.ស.) |

**អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

-ទទួលអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃសរុបចំនួន ៥.០៨៥នាក់

-បញ្ចូលបន្ទុកអតីតយុទ្ធជន ១២០នាក់ និងលុបបន្ទុកអតីតយុទ្ធជន ២.៥៥៦នាក់

-ផ្ទេរអតីតយុទ្ធជនតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត ២១៨នាក់ និងទទួលស្គាល់របបឧបត្ថម្ភឡើងវិញ ១១នាក់

-ផ្តល់ប្រាក់បូជាសព មួយលើកដំបូង និងប្រាក់ធានារ៉ាប់រងសង្គម ៧២៨នាក់

-ផ្តល់ប្រាក់វិលទៅមូលដ្ឋានមួយលើកដំបូងជូនជនពិការ ៩៨៦នាក់

<u>តារាងទី៨៖ កំណត់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារក្នុងឆមាសទី១ ឆ្នាំ២០២១</u>

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវទទួលរបប | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ៧ | ៣ | ៥ | | ៥ | ៧ | | ២០ | ២០៩.០០០៛ |
| ២ | ជនមរណៈ | ១៤៦ | ៣៤ | ៧៥ | ២ | ១២៧ | ១៤៨ | | ៣៨៦ | ៤.២៧៣.០០០៛ |
| ៣ | ជនពិការ | ១.៥៤១ | | | | ១.២០៣ | ៩៥៤ | ២១៩ | ២.៣៧៦ | ១.៩៦៨.៩៧១.៨០០៛ |
| ៤ | និវត្តជន | ២.៧៧៥ | | | | ២.៣៩៤ | ២.៣៤១ | | ៤.៧៣៥ | ៣.១២០.១៦៤.០៦៦៛ |
| ៥ | ជនបាត់បង់ | ១ | | | | ១ | | | ១ | ១.០៨៣.៣៧៥៛ |
| សរុប | | ៤.៤៧០ | ៣៧ | ៨០ | ២ | ៣.៧៣០ | ៣.៤៥០ | ២១៩ | ៧.៥១៨ | ៥.០៩៤.៧០១.២៤១៛ |

(ប្រភព ប.ជ.អ.)

<u>តារាងទី៩៖ លុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព និងទទួលស្គាល់ជាជនពលី និងមរណៈវិញ</u>

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលទទួលប្រាក់ឧបត្ថម្ភក្នុងឆមាសទី១ ឆ្នាំ ២០២១ | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពិការ | ២០៨ | ២៤ | | | ១៩៧ | ៩៤ | | ៣១៥ | ៤.០៨៧.០០០៛ |
| ២ | និវត្តជន | ៣៦៧ | ៦ | ៨ | | ៣៥១ | ១០២ | | ៤៦៧ | ៦.៣៩៧.០០០៛ |
| ៣ | ជនបាត់បង់ | ៥ | | ១ | | ៤ | ១ | | ៦ | ៧៨.០០០៛ |
| សរុប | | ៥៨០ | ៣០ | ០៩ | | ៥៥២ | ១៩៧ | | ៧៨៨ | ១០.៥៦២.០០០៛ |

(ប្រភព ប.ជ.អ.)

<u>តារាងទី១០៖ លុបឈ្មោះអតីតយុទ្ធជន និងគ្រួសារចេញពីបញ្ជីបើកប្រាក់ក្នុងឆមាសទី១ ឆ្នាំ២០២១</u>

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវកាត់ចេញ | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ១៨០ | ៣៧ | ៩៨ | | ៧៣ | ១៨ | | ២២៦ | ២.៣៥៥.០០០៛ |
| ២ | ជនមរណៈ | ២៦ | ៤ | ៥ | ១ | ៨ | ១៤ | | ៣២ | ៣៤០.០០០៛ |
| ៣ | ជនពិការ | ៥៣ | | | | | | | | ៣៨.៦៧៦.៦៦៣៛ |
| ៤ | និវត្តជន | ៤៨ | | | | | | | | |
| ៥ | ជនបាត់បង់ | ១ | | | | | | | | |
| សរុប | | ៣០៨ | ៤១ | ១០៣ | ១ | ៨១ | ៣២ | | ២៥៨ | ៤១.៣៧១.៦៦៣៛ |

(ប្រភព ប.ជ.អ.)

<u>តារាងទី១១៖ អតីតយុទ្ធជន និងគ្រួសារដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គមក្នុងឆមាសទី១ឆ្នាំ២០២១</u>

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវទទួលរបប | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ២៦.៧៨៩ | ៥.៦៣៤ | ១០.៩៤៦ | ១៧៦ | ២០.២៦៨ | ៨.១៣៤ | | ៤៥.១៥៨ | ៥១៩.៥១៤.០០០៛ |
| ២ | ជនមរណៈ | ៩.១៥៥ | ១.១៨៤ | ២.២១៦ | ៣២ | ៨.៤៣៥ | ៤.៧៦៨ | | ១៦.៦៣៥ | ២០១.៧៦១.០០០៛ |
| ៣ | ជនពិការ | ២៨.៥៨៤ | | | | ២៤.២៧៣ | ១៣.៦៣៦ | ១.៦៣០ | ៣៩.៥៣៩ | ២១.៦៩២.៤៥៦.៣៤៣៛ |
| ៤ | និវត្តជន | ៣៥.៦៥៧ | | | | ៣០.០៩២ | ១៥.៦១១ | | ៤៥.៧០៣ | ៣០.១៥៣.០៨៤.៥៧៨៛ |
| ៥ | ជនបាត់បង់ | ១.៤៨៣ | | | | ១.១០៦ | ៤៩៤ | ៦៤ | ១.៦៦៤ | ៩៥៤.១៥៩.៣២៣៛ |
| សរុប | | ១០១.៦៦៨ | ៦.៨១៨ | ១៣.១៦២ | ២០៨ | ៨៤.១៧៤ | ៤២.៥៤៣ | ១.៦៩៤ | ១៤៨.៦៩៩ | ៥៣.៥២០.៩៧៥.២៤៤៛ |

(ប្រភព ប.ជ.អ.)

**អនុកម្មវិធីទី២.៣.ការបន្តនិងពង្រឹងការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

-បានទទួលប្រាក់ភាគទានពីក្រសួង ស្ថាប័ន និងនីតិបុគ្គលដែលមិនបានជ្រើសរើសជនពិការចូលបម្រើការងារចំនួន ១៦.៩៩០.៣៦០៛

-គ្លីនិកព្យាបាលដោយចលនាបានទទួលអតិថិជនមកព្យាបាល ដោយទទួលបានថវិកាសរុបចំនួន ២៧០.០០០៛

-បានដាក់ហិបមូលនិធិជនពិការនៅតាមរាជធានី/ខេត្ត និងប្រមូលបានថវិកាសរុបចំនួន ២៩.២៣១.០០០៛

-មូលនិធិជនពិការតាមរយៈមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងអង្គការដៃគូបានផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនពិការ ២០.១៤០នាក់ ក្នុងនោះសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ៧.៣៥២នាក់ និងស្តារវេជ្ជសាស្ត្រ ១២.៧៨៨នាក់

-បានប្រគល់ផ្ទះជូនជនពិការក្រីក្រចំនួន ០៣ខ្នង នៅខេត្តបន្ទាយមានជ័យ ០២ខ្នង និងខេត្តឧត្តរមានជ័យ ០១ខ្នង

-បានផ្តល់អំណោយសប្បុរសធម៌ជារបស់ ម.ជ.ព. ជូនជនពិការក្រីក្រចំនួន ៣៩៨នាក់ នៅខេត្តកណ្តាល កំពង់ស្ពឺ កែប ព្រៃវែង បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពត ត្បូងឃ្មុំ ស្វាយរៀង និងខេត្តឧត្តរមានជ័យ

-បានផ្តល់ប្រាក់ឧបត្ថម្ភរបបគោលនយោបាយសម្រាប់ពិនិត្យ និងថែទាំសុខភាពជូនជនពិការក្រីក្រនៅតាមសហគមន៍ចំនួន ៧៣២នាក់ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំដោយម្នាក់ៗទទួលបានថវិកា ៣០.០០០៛។

២.៣.១.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា

-ដោយមានការសហការជួយឧបត្ថម្ភរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានកិច្ចសហការជាមួយក្រសួង ស.អ.យ. មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងរោងជាងសរុបចំនួន ១៥កន្លែង បានផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាគ្រប់ប្រភេទជូនជនពិការសរុបចំនួន ៧.៣៥២នាក់ ស្រី ១.៩១៣នាក់ និងជនពិការដោយសារមីន ២.៥០០នាក់។ទន្ទឹមនេះ ជនពិការដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មដោយឥតគិតថ្លៃ ព្រមទាំងបានទទួលការឧបត្ថម្ភជាប្រាក់អាហារ និងថ្លៃធ្វើដំណើរទៅមកផងដែរ

-បានផ្តល់អវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយការពារកាយសរុបចំនួន ៣.១៦៨គ្រឿង/រាយ

-បានជួសជុលឧបករណ៍សិប្បនិម្មិត រណប និងឧបករណ៍ជំនួយរាងកាយសរុបចំនួន ៣.៩៩៥គ្រឿង/រាយ

-បានព្យាបាលដោយចលនាចំនួន ២.៩៨៤នាក់ ស្មើនឹងចំនួនព្យាបាល ១៩.៧៥៨ដង

-ផ្តល់ការស្នាក់នៅជូនជនពិការអំឡុងពេលទទួលសេវាបាន ២.៣៣២នាក់ និងអ្នកកំដរ ៤៤៥នាក់។

២.៣.២.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ

បានពិនិត្យ និងព្យាបាលវះកាត់ភ្នែក ដាក់កែវភ្នែកសិប្បនិម្មិត ដាក់កញ្ចក់ក្នុងកែវភ្នែក ផ្តល់វ៉ែនតាវះកាត់ដៃជើងនិងមុខមាត់ ព្យាបាលជំងឺហង់សិន និងព្យាបាលអ្នកជំងឺរបួសខួរឆ្អឹងខ្នងបានចំនួនសរុប ១២.៧៨៨នាក់ស្រី៦.៩៥៤នាក់។

២.៣.៣.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍

-ជនពិការបានទទួលសេវាជួសជុលចល័ត ១.១២៣នាក់

-បានផ្តល់ រទេះរុញនិងរទេះកង់បី ៧៧គ្រឿង ឈើច្រត់ ១០៦រាយ និងស្បែកជើងខ្ពស់ទាប ៣៥គូ

-បានបញ្ជូនជនពិការទៅកាន់អង្គការឬអ្នកផ្តល់សេវាផ្សេងៗ ទៀត ១៣៤នាក់

-បានបញ្ជូនកុមារពិការទៅសាលារដ្ឋ១០៤នាក់

-បានស្រាវជ្រាវឃើញជនពិការថ្មីដែលត្រូវបញ្ជូនទៅទទួលសេវានៅមណ្ឌល ១៣នាក់

-បានផ្តល់កង់ជូនជនពិការចំនួន ១៥នាក់

-ចំនួនអាជីវកម្មខ្នាតតូចដែលបានបង្កើត ១៩នាក់

-បានចុះសួរសុខទុក្ខអ្នកជំងឺនៅក្នុងសហគមន៍ ២២២នាក់។

## កម្មវិធីទី៣.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ

### អនុកម្មវិធីទី៣.១.ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ

#### ៣.១.១.ការងាររដ្ឋបាល និងបុគ្គលិក

-បានរក្សាទុក និងតម្កល់លិខិតបទដ្ឋានគតិយុត្ត មានសណ្តាប់ធ្នាប់ របៀបរៀបរយ ត្រឹមត្រូវ និងលាក់ការណ៍សម្ងាត់

-ក្របខ័ណ្ឌមន្ត្រីរាជការសរុបចំនួន ១.៧៧៤នាក់ ស្រី ៦៦៩នាក់ (ថ្នាក់ជាតិ ៩៤៣នាក់ និងក្រោមជាតិ ៨៣១នាក់)

-តែងតាំង និងប្រគល់ភារកិច្ច ៧៥នាក់

-ផ្ទេរចេញក្រៅក្រសួង ០៨នាក់និងផ្ទេរផ្ទៃក្នុងក្រសួង ១២នាក់

-លុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌ០៥នាក់

-ការផ្ទេរក្របខ័ណ្ឌចូលក្រសួង ០៧នាក់ ចូលនិវត្តន៍ ១៤នាក់ និងសម្រួលការកិច្ច០៧នាក់

-ការរៀបប្រាក់បៀវត្សមន្ត្រីរាជការដែលតែងតាំង ៧០នាក់

-ការរៀបប្រាក់បៀវត្សដែលដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ២៦៤នាក់

-ការផ្តាច់ប្រាក់មន្ត្រីឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ០២នាក់

-ការផ្តាច់ប្រាក់បៀវត្សមន្ត្រីចូលនិវត្តន៍ ០៥នាក់

-លំហែមាតុភាព ១០នាក់

-ផ្តល់ប្រាក់ឧបត្ថម្ភអ្នកនៅក្នុងបន្ទុកមន្ត្រីរាជការ ៣៧នាក់ និងផ្តាច់ប្រាក់ឧបត្ថម្ភអ្នកនៅក្នុងបន្ទុក ១៤នាក់

-បានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ក្នុងប្រទេស ៧៥នាក់ និងក្រៅប្រទេស ០១នាក់។

#### ៣.១.២.ការងារផែនការ ស្ថិតិ និងសរុប

-បានរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាសទី១ និងឆមាសឆ្នាំ២០២១

-បានរៀបចំសេចក្តីព្រាងផែនការសកម្មភាព ៣ឆ្នាំរំកិល ២០២១-២០២៣

-បានរៀបចំកម្មវិធីវិនិយោគសាធារណៈ ២០២០-២០២៤ របស់ក្រសួង មាន ៧គម្រោង ក្នុងនោះ គម្រោងកំពុងអនុវត្ត ០១គម្រោង

-បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត នៅខេត្តត្បូងឃ្មុំ មានអ្នកចូលរួមចំនួន ៣៤០នាក់។

#### ៣.១.៣.ការងារគ្រប់គ្រងថវិកា និងសម្ភារ

-បានបើកប្រាក់បៀវត្សរ៍ប្រចាំខែ ជូនមន្ត្រីរាជការ បានទាន់ពេលវេលា

-បានផ្គត់ផ្គង់សម្ភារ បរិក្ខារ សង្ហារឹម ការជួសជុល និងប្រេងឥន្ធនៈ ជូនថ្នាក់ដឹកនាំ និងអង្គភាពក្រោមឱវាទ។

#### ៣.១.៤.ការងារសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន

-បានចុះត្រួតពិនិត្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១១ និងបានចុះកិច្ចព្រមព្រៀងជាមួយអង្គការចំនួន ១០

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអង្គការដែលចុះកិច្ចព្រមព្រៀងនៅមានសុពលភាពជាមួយក្រសួងចំនួន ១៥៤ដែលមានថវិកាសរុបចំនួន ៣០៤.៨៣៦.៦៣០,៥០ដុល្លារអាមេរិក

-បានសម្របសម្រួលផ្តល់លិខិតគាំទ្រសម្រាប់អង្គការស្នើសុំបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជូនអង្គការ ១០ករណី

-លិខិតគាំទ្រនាំចូលរថយន្តរបស់អង្គការមិនមែនរដ្ឋាភិបាលដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋចំនួន ៤គ្រឿង

-លិខិតគាំទ្រស្នើសុំស្លាកលេខប្រភេទអង្គការចំនួន ៤

-លិខិតគាំទ្រពន្យាទិដ្ឋាការជូនបុគ្គលិកសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤។

#### ៣.១.៥.ការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង

-ក្នុងឆមាសទី១ ឆ្នាំ២០២១នេះ ក្រសួងបានចុះធ្វើសវនកម្មនៅខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបងចំពោះការងារអធិការកិច្ចមិនមានវិវាទការងារ ឬពាក្យបណ្តឹង សម្រាប់ដោះស្រាយឡើយ។

### អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស

-សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ វិទ្យាស្ថានជាតិសង្គមកិច្ចមាននិស្សិត ៤៤១នាក់ ស្រី ២៥៨នាក់ កំពុងបន្តការសិក្សា។

## II-ទិសដៅអនុវត្តបន្ត

### កម្មវិធីទី១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

### អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ

-បន្តដំណើរការកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ដើម្បីឆ្លើយតបនឹងបញ្ហាកង្វះអាហារូបត្ថម្ភ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រនិងងាយរងគ្រោះក្នុងអំឡុងជំងឺកូវីដ.១៩។

-ដោះស្រាយបញ្ហាជនអនាថាតាមរយៈការផ្ដល់សេវាអប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ការថែទាំសុខភាព ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈបង្កឱកាសស្ដារជីវភាពនិងធ្វើសមាហរណកម្មទៅក្នុងសង្គម ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស

-ទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ តាមរយៈការផ្សព្វផ្សាយអប់រំ បញ្ជ្រាបការយល់ដឹងស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

-បន្តកម្មវិធីផ្ដល់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ជនក្រីក្រ ជនរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយថាហេតុផ្សេងៗ

-ពង្រឹងដំណើរការមជ្ឈមណ្ឌលទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី និងការទទួលជនវិបល្លាសស្មារតីមកស្នាក់នៅ ផ្ដល់សេវាថែទាំ

-បន្តផ្ដល់សេវាថែទាំគាំទ្រដល់ជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺ កាចសាហាវផ្សេងៗ

-អនុវត្តកម្មវិធីអភិវឌ្ឍគ្រួសារល្អ ការចិញ្ចឹមកូនបែបវិជ្ជមាន ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

-បន្តពង្រឹងប្រសិទ្ធភាព និងការគ្រប់គ្រងមជ្ឈមណ្ឌលសំចតសង្គមកិច្ច

-បន្តបញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងលើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្តនានា ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

-ផ្ដល់កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចនិងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន និងដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្ដីពីយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចនិងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន

-ផ្ដល់សេវាការពារផ្លូវច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សអំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចនិងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន

-ប្រឹក្សាយោបល់ បញ្ជូនទៅស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈសមាហរណកម្ម ប៉ាន់ប្រមាណគ្រួសារ និងតាមដានដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សអំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចនិងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន

-ទទួល និងធ្វើមាតុភូមិនិវត្តជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចនិងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន

-ពង្រឹងដំណើរការមជ្ឈមណ្ឌលសំចតប៉ោយប៉ែតសម្រាប់ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស

-បន្តសហការជាមួយសាលាដំបូង រាជធានី ខេត្តទាំង២៥ សម្របសម្រួលសាក្សី និងជនរងគ្រោះក្នុងដំណើរការប្រព័ន្ធតុលាការ ករណីអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ អំពើរំលោភបំពានលើកុមារ និងយុត្តិធម៌អនីតិជន

-រៀបចំបែបបទផ្ដល់នីតិសម្បទា ដល់មជ្ឈមណ្ឌលថែទាំជនរងគ្រោះរបស់អង្គការ

-បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដើម្បីជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

### អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

-បន្តផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារទាំងបីដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារដែលក្រសួងបានផ្ទេរ និងត្រួតពិនិត្យវាយតម្លៃគុណភាពសេវាដែលបានផ្ដល់ដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

-បន្តត្រួតពិនិត្យនិងវាយតម្លៃអង្គការ និងចេញវិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំកុមារ

-លើកកម្ពស់សមត្ថភាពគ្រប់គ្រងមណ្ឌលថែទាំកុមារដោយផ្ដោតលើគុណភាពសេវាការគ្រប់គ្រងករណីការបង្រួបបង្រួមគ្រួសារសមាហរណកម្មនិងជំរុញកម្មវិធីបង្វែរសេវាថែទាំកុមារនៅក្នុងមណ្ឌលទៅជាការថែទាំនៅតាមសហគមន៍

-ពង្រឹងពង្រីកគុណភាពសេវាថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍ដោយផ្តោតលើកុមារដែលបានបង្រួបបង្រួមគ្រួសារនិងកុមារកំពុងស្នាក់នៅកន្លែងថែទាំដូចជាផ្ទះស្នាក់នៅបណ្តោះអាសន្នផ្ទះជាក្រុមវត្តអារាមសាសនានានានិងអន្តេវាសិកដ្ឋាន រួមទាំងការថែទាំដោយឪពុកម្តាយធម៌ការថែទាំពេលថ្ងៃនិងពេលយប់និងបណ្តុះបណ្តាលជំនាញចិញ្ចឹមកូនបែបវិជ្ជមាន

-បន្តសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ជនបង្គោលរាជធានី ខេត្ត ក្នុងការចុះអន្តរាគមន៍ សម្របសម្រួល និងដោះស្រាយករណីរំលោភបំពានលើកុមារដែលស្នាក់នៅក្នុងមណ្ឌល

-បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីអង្គការសុវត្ថិភាពកុមារដល់អង្គការដែលធ្វើការពាក់ព័ន្ធនឹងសុខុមាលភាពកុមារ និងចុះត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តបទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ

-បន្តកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានា ដែលមានបំណងធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសជាមួយកម្ពុជា និងផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស

-ពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១

-បន្តផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ និងកសាងច្បាប់ ស្តីពីកិច្ចការពារកុមារនៅកម្ពុជា

-រៀបចំ និងផ្សព្វផ្សាយ លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធសិទ្ធិនិងការការពារកុមារ

-ដាក់ឱ្យដំណើរការមណ្ឌលយុវនីតិសម្បទាដើម្បីទទួលអនីតិជនទំនាស់នឹងច្បាប់ឱ្យស្នាក់នៅ និងស្តារនីតិសម្បទា

-រៀបចំកម្មវិធីបណ្តុះបណ្តាលបំណិនជីវិតនិងជំនាញវិជ្ជាជីវៈដល់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

-ផ្សព្វផ្សាយ អប់រំកុមារយុវជនទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គមរួមចំណែកលើកស្ទួយសីលធម៌សុជីវធម៌ និងការពារសិទ្ធិរបស់កុមារនិងអនីតិជនទំនាស់នឹងច្បាប់

-បន្តចុះពិនិត្យស្ថានភាពរស់នៅរបស់អនីតិជនដែលកំពុងរស់នៅក្នុងមណ្ឌលអប់រំ កែប្រែ និងពន្ធនាគារ

-សហការ និងសម្របសម្រួលក្នុងការផ្តល់សេវាសង្គមកិច្ចដល់កុមារតាមម្តាយក្នុងពន្ធនាគារ

-ទទួល ព្យាបាល បន្សាប ស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន នៅក្នុងមណ្ឌល និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលព្យាបាល បន្សាប និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅកែវផុស ខេត្តព្រះសីហនុ

-លើកទឹកចិត្តការព្យាបាលនិងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍ និងលើកកម្ពស់ការចូលរួមទទួលខុសត្រូវ របស់ឪពុកម្តាយសាច់ញាតិ។

**អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ**

-បន្តអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ តាមរយៈការរៀបចំរបាយការណ៍ជាតិស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការជូនអង្គការសហប្រជាជាតិនិងពិធីសារបន្ថែមផ្សេងៗ

-ផ្តល់សេវាផ្លូវច្បាប់សម្រាប់ជនពិការដែលមានតម្រូវការចាំបាច់ ដោយសហការជាមួយស្ថាប័នតុលាការ មន្ត្រីយុត្តិធម៌ និងបុគ្គលិកពន្ធនាគារ

-បន្តធ្វើវិសោធនកម្មច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

-ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ

-រៀបចំទិវាជនពិការជាតិ អន្តរជាតិ និងទិវាផ្សេងៗពាក់ព័ន្ធជនពិការ

-បន្តតាមដានការអនុវត្តស្តង់ដាអប្បបរមានៃការបង្កលក្ខណៈងាយស្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មធ្យោបាយធ្វើដំណើរ និងទំនាក់ទំនងសម្រាប់ជនពិការ

-បន្តអនុវត្តការផ្តល់របបគោលនយោបាយឧបត្ថម្ភជនពិការក្រីក្រនៅតាមសហគមន៍

-បន្តការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ដោះស្រាយការងារ និងមុខរបរជូនជនពិការ

-បន្តសហការជាមួយអង្គការដៃគូក្នុងការអនុវត្តកម្មវិធីផ្តល់សេវាជូនកុមារពិការភ្នែក កុមារគរថ្លង់ និងកុមារពិការខ្សោយសតិបញ្ញាតាមរយៈការអប់រំ និងសេវាពិសេសជូនដល់ប្រភេទកុមារពិការនីមួយៗ

-លើកទឹកចិត្តចលនាកីឡាសិល្បៈរបស់ជនពិការ ការងារព័ត៌មានជាភាសាសញ្ញា និងការអភិវឌ្ឍសេវាអក្សរស្ទាប និងភាសាសញ្ញា។

**អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

-បន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សមាគមមនុស្សចាស់

-ពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងអនុគណៈកម្មាធិការដើម្បីមនុស្សចាស់ថ្នាក់រាជធានី ខេត្ត

-ជំរុញដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់ ដើម្បីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ថែទាំមនុស្សចាស់

-រៀបចំផែនការសកម្មភាព ២០២១-២០២៥ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់២០១៧-២០៣០។

**អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន**

-បន្តបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ នៅតាមសហគមន៍ឃុំ សង្កាត់

-បន្តបង្កើតគណៈកម្មការអភិវឌ្ឍន៍អតីតយុទ្ធជនឃុំ សង្កាត់ នៅតាមរាជធានី ខេត្ត សំដៅជួយដល់អតីតយុទ្ធជនក្នុងការសាមគ្គីភាព និងកសាងជីវភាពគ្រួសារចូលរួមអភិវឌ្ឍន៍នៅតាមមូលដ្ឋាន

-បន្តទទួល ពិនិត្យ និងផ្ទៀងផ្ទាត់លើសំណុំបែបបទស្នើសុំប្រាក់បេឡាមរណសង្គ្រោះ

-បន្តសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីអនុវត្តបេឡាមរណសង្គ្រោះ ស្របតាមលក្ខន្តិកៈ ស.អ.ក. និងពង្រឹងការចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច។

**កម្មវិធីទី២.ការបង្កើនប្រសិទ្ធិភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ**

**អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**

-ពង្រឹង និងបង្កើនប្រសិទ្ធភាពផ្នែកសោធន តាមរយៈការបើកផ្តល់របបសន្តិសុខសង្គមជូននិវត្តជន ជនបាត់បង់សម្បទា-វិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក

-បន្តសិក្សា និងដាក់ឱ្យអនុវត្តតាវកាលិក គ្រោះថ្នាក់ការងារ មាតុភាព និងមរណភាព

-បន្តសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម ក្នុងការផ្តល់សេវាធានារ៉ាប់រងថែទាំសុខភាពសម្រាប់មន្ត្រីរាជការស៊ីវិល

-បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

-បន្តចេញប្រកាសទទួលស្គាល់ និងគ្រប់គ្រងអតីតមន្ត្រីរាជការស៊ីវិលដែលផ្ទេរមកក្រសួង ស.អ.យ

-បន្តធ្វើបច្ចុប្បន្នភាពសិទ្ធិវន្ត ប.ជ.ស នៅតាមរាជធានី ខេត្ត និងអនុវត្តការបើកផ្តល់របបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព

-បន្តពិនិត្យ កែសម្រួលប្រាក់របបសន្តិសុខសង្គមជូនដល់អតីតមន្ត្រីរាជការស៊ីវិល

-បន្តផ្ទេរសិទ្ធិជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានជំងឺមិនអាចទៅបើកប្រាក់សោធនប្រចាំខែនៅតាមធនាគារ។

**អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

-បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ដោយប្រមូលផ្តុំលើ ការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងអ្នកនៅក្នុងបន្ទុកនិងប្រាក់គោលនយោបាយមរណភាពជូនដល់គ្រួសារអតីតយុទ្ធជនឱ្យបានទាន់ពេលវេលា ការពង្រឹងកិច្ចសហការល្អជាមួយធនាគារ គ្រឹះស្ថានសាធារណៈ និងសហគ្រាសឯកជន ការបន្តធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិនិងក្រសួងមហាផ្ទៃនៅតាមរាជធានីខេត្ត ការចេញលិខិតផ្ទេរសិទ្ធិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែជូនអតីតយុទ្ធជន និងគ្រួសារ និងការសិក្សាស្រាវជ្រាវបន្ថែមការដាក់ឱ្យអនុវត្តការប្រមូលភាគទានសម្រាប់ទ្រទ្រង់ ប.ជ.អ.

-បន្តពិនិត្យកែសម្រួលរបបសន្តិសុខសង្គម តាមរយៈការកាត់បន្ថយគម្លាតនៃរបបសោធនរបស់នគរបាលជាតិ និងយោធិននៃកងយោធពលខេមរភូមិន្ទ

-បន្តសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម ក្នុងការផ្តល់សេវាធានារ៉ាប់រងថែទាំសុខភាពជូនអតីតយុទ្ធជន។

**អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

-បន្តនិរន្តរភាពកម្មវិធីស្តារលទ្ធភាពពលកម្មជូនជនពិការដោយឥតគិតថ្លៃរួមទាំងការផ្តល់សោហ៊ុយធ្វើដំណើរ និងការស្នាក់នៅ និងបន្តផលិតឧបករណ៍សិប្បនិម្មិត និងរណប

-បន្តពង្រឹង ពង្រីកការដាក់ហិបមូលនិធិជនពិការនៅតាមរាជធានី ខេត្ត និងបន្តផ្តល់សេវាព្យាបាលដោយចលនាដោយបង់ប្រាក់

-បន្តអនុវត្តការផ្តល់របបគោលនយោបាយថែទាំសុខភាពជូនជនពិការក្រីក្រនៅតាមរាជធានី ខេត្ត

-បន្តចុះត្រួតពិនិត្យ វាយតម្លៃលក្ខណៈវិនិច្ឆ័យ និងសាងសង់ផ្ទះជូនជនពិការក្រីក្រ

-បន្តអនុវត្តកម្មវិធីសេវាសហគមន៍សម្រាប់ជនពិការ ការអភិវឌ្ឍមុខរបរខ្នាតតូច និងជំរុញឱ្យទទួលបានការអប់រំ និងឱកាសការងារ

-ប្រមូលភាគទានប្រាក់ពិន័យអន្តរការណ៍ ចំពោះស្ថាប័ននានា និងនីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ

-ផ្សព្វផ្សាយច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងសេវាស្តារលទ្ធភាពពលកម្មដើម្បីអប់រំ បញ្ជ្រាបការយល់ដឹងដល់សាធារណជន និងលើកទឹកចិត្តជនពិការឱ្យទទួលបាននូវអត្ថប្រយោជន៍នានាដែលមានក្នុងច្បាប់។

**កម្មវិធីទី៣.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិបាលភាពជាដៃគូ**

**អនុកម្មវិធីទី៣.១.ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងភាពជាដៃគូ**

-ពង្រឹងសមត្ថភាពមន្ត្រីរាជការនិងបង្កើនប្រសិទ្ធភាពការងារ ដោយប្រមូលផ្តុំលើការងារ រៀបចំផែនការក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី ការពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ តាមរយៈ ការអនុវត្តច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បទបញ្ជាផ្ទៃក្នុងនិងរបៀបរបបធ្វើការឱ្យបានម៉ឺងម៉ាត់

-លើកទឹកចិត្តមន្ត្រីគ្រប់លំដាប់ថ្នាក់ តាមរយៈ ការដំឡើងឋានៈ តួនាទី ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗ

-ពង្រឹងការងារផែនការនិងផ្សព្វផ្សាយតាមរយៈ ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពនិងលទ្ធផលការងាររបស់អង្គភាពចំណុះ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងការផ្សព្វផ្សាយលទ្ធផលការងារដែលក្រសួងសម្រេចបាន

-បន្តអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រដ្ឋ រួមមាន កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងបន្តគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥

-ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ សំដៅជួយដល់ជនរងគ្រោះគ្រប់មុខសញ្ញា

-ពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនានា ក្នុងតំបន់អាស៊ាន និងសាកលលោក

-ចុះធ្វើសវនកម្មផ្ទៃក្នុងនៅតាមអង្គភាពចំណុះក្រសួង សំដៅពង្រឹងការគ្រប់គ្រងប្រើប្រាស់ថវិកាឲ្យមានប្រសិទ្ធភាពខ្ពស់

-បន្តចុះធ្វើអធិការកិច្ច សំដៅពង្រឹងប្រសិទ្ធភាពការងារ ការគ្រប់គ្រងមន្ត្រីរាជការ និងទទួលពាក្យបណ្តឹង ព្រមទាំងអន្តរាគមន៍ដោះស្រាយវិវាទផ្សេងៗ។

**អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស**

-បន្តពង្រឹង និងពង្រីកសមត្ថភាពរបស់វិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្សសម្រាប់អភិវឌ្ឍសង្គម តាមរយៈការរៀបចំផែនការ សិក្សាស្រាវជ្រាវអភិវឌ្ឍកម្មវិធីសិក្សា ផ្សារភ្ជាប់ការចុះអនុវត្តជាក់ស្តែង៕

ថ្ងៃ សៅរ៍ ខែ ទុតិយាសាឍ ឆ្នាំឆ្លូវត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**វង សូត**